| 2 | 394781.068 | 1491049.216 | 19 | 394664.794 | 1490826.374 | 36 | 394229.775 | 1490841.243 | 53 | 393665.855 | 1490640.369 | 70 | 394425.67 | 1491168.121 |
| 3 | 394786.974 | 1491049.477 | 20 | 394594.192 | 1490800.543 | 37 | 394199.027 | 1490842.459 | 54 | 393614.649 | 1490640.369 | 71 | 394445.799 | 1491167.195 |
| 4 | 394798.347 | 1491050.981 | 21 | 394525.57 | 1490781.748 | 38 | 394101.741 | 1490841.925 | 55 | 393609.648 | 1490640.369 | 72 | 394461.477 | 1491164.44 |
| 5 | 394813.615 | 1491055.257 | 22 | 394524.432 | 1490781.487 | 39 | 394039.582 | 1490838.093 | 56 | 393609.645 | 1491091.731 | 73 | 394483.564 | 1491156.993 |
| 6 | 394837.718 | 1491063.72 | 23 | 394521.809 | 1490780.888 | 40 | 394033.561 | 1490837.62 | 57 | 393632.308 | 1491093.853 | 74 | 394490.186 | 1491154.379 |
| 7 | 394854.424 | 1491068.423 | 24 | 394447.493 | 1490767.505 | 41 | 394019.241 | 1490836.187 | 58 | 393925.701 | 1491121.32 | 75 | 394518.415 | 1491143.233 |
| 8 | 394870.746 | 1491072.018 | 25 | 394456.577 | 1490690.53 | 42 | 394003.428 | 1490834.604 | 59 | 393936.741 | 1491122.354 | 76 | 394598.077 | 1491111.78 |
| 9 | 394881.721 | 1491073.885 | 26 | 394446.68 | 1490689.268 | 43 | 393936.741 | 1490824.037 | 60 | 393952.601 | 1491123.839 | 77 | 394619.695 | 1491104.152 |
| 10 | 394884.424 | 1491069.273 | 27 | 394383.651 | 1490683.648 | 44 | 393906.651 | 1490817.47 | 61 | 394002.304 | 1491131.97 | 78 | 394641.73 | 1491096.378 |
| 11 | 394919.942 | 1490999.744 | 28 | 394380.055 | 1490683.454 | 45 | 393861.255 | 1490805.369 | 62 | 394019.241 | 1491134.742 | 79 | 394673.494 | 1491085.171 |
| 12 | 394960.613 | 1490881.653 | 29 | 394357.542 | 1490780.036 | 46 | 393857.665 | 1490804.296 | 63 | 394101.741 | 1491148.239 | 80 | 394715.002 | 1491069.739 |
| 13 | 394960.629 | 1490881.587 | 30 | 394341.557 | 1490797.452 | 47 | 393846.706 | 1490800.103 | 64 | 394178.175 | 1491160.745 | 81 | 394747.752 | 1491057.563 |
| 14 | 394947.079 | 1490881.912 | 31 | 394323.138 | 1490811.838 | 48 | 393799.413 | 1490725.769 | 65 | 394239.686 | 1491170.808 | 82 | 394769.651 | 1491050.97 |
| 15 | 394883.598 | 1490879.583 | 32 | 394319.662 | 1490814.127 | 49 | 393799.761 | 1490722.869 | 66 | 394255.512 | 1491172.753 | | | |
| 16 | 394808.467 | 1490869.483 | 33 | 394295.691 | 1490826.93 | 50 | 393832.178 | 1490643.233 | 67 | 394264.943 | 1491173.26 | | | |
| 17 | 394735.495 | 1490851.698 | 34 | 394278.598 | 1490833.315 | 51 | 393834.462 | 1490640.369 | 68 | 394291.391 | 1491172.213 | | | |

ចំណោលផែនទី UTM (Universal Transvers Mercator), Zone48N
ជាតុម WGS 1984

បានឃើញ និងឯកភាព
ថ្ងៃទី ...... ខែ ...... ឆ្នាំ ២០២២
អគ្គនាយកអាជ្ញាធរជាតិអប្សរា

ហង់ ពៅ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ..១០.. ខែ ..កក្កដា.. ឆ្នាំ ២០២២
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប

អ៊ឹ សាឃឿ

ថ្ងៃទី ..០៥.. ខែ..កក្កដា.. ឆ្នាំ ២០២២
វាស់វែង និងគូរ: ......................
- ដួង-ទិត

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកាត់ឆ្វៀលដីទំហំ១ហិកតា៨៣អា ស្ថិតនៅភូមិកណ្ដាល ឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ជូនកងទ័ពជើងគោក នៃក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១ .-**

ត្រូវបានកាត់ឆ្វៀលដីទំហំ១ហិកតា៨៣អា(មួយហិកតាប៉ែតសិបបីអា) ស្ថិតនៅភូមិកណ្ដាល ឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ជូនកងទ័ពជើងគោក នៃក្រសួងការពារជាតិ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា១ ជូនក្រសួងការពារជាតិ ដើម្បីធ្វើការគ្រប់គ្រង និងចាត់ចែងស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣ រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




| N | X | Y |
|---|---|---|
| 1 | 260941 | 1396206 |
| 2 | 261043 | 1396305 |
| 3 | 261111 | 1396303 |
| 4 | 261134 | 1396311 |
| 5 | 261232 | 1396247 |
| 6 | 261246 | 1396229 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៥៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកំណត់ផ្ទៃដីទំហំ ១១ ១៧៧ (ដប់មួយពាន់ មួយរយចិតសិបប្រាំពីរ) ហិកតា ស្ថិតក្នុងឧទ្យានជាតិ ព្រះមុនីវង្ស "បូកគោ" ជាតំបន់ប្រើប្រាស់ដោយចីរភាព ក្នុងភូមិសាស្ត្រខេត្តកំពត និងខេត្តព្រះសីហនុ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កំណត់ផ្ទៃដីទំហំ ១១ ១៧៧ (ដប់មួយពាន់ មួយរយចិតសិបប្រាំពីរ) ហិកតា ស្ថិតក្នុងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ជាតំបន់ប្រើប្រាស់ដោយចីរភាព ក្នុងភូមិសាស្ត្រខេត្តកំពត និងខេត្តព្រះសីហនុ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងចុះបញ្ជីជូនក្រសួងបរិស្ថាន។

**មាត្រា២ .-**

អនុញ្ញាតជូនក្រុមហ៊ុន សុខា អូតែល ធ្វើការអភិវឌ្ឍទីតាំងដីដូចមានចែងក្នុងមាត្រា១ ខាងលើ ស្របតាមកិច្ចសន្យាស្ដីពីការជួលដីសម្រាប់គម្រោងអភិវឌ្ឍន៍ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ដោយអភិរក្សទីតាំងដែលមានគុណតម្លៃជីវៈចម្រុះ តំបន់ដែលមានអេកូឡូស៊ីផុយស្រួយ តំបន់ទីជម្រាល និងផ្ទៃរងទឹកភ្លៀង និងរបៀងសត្វព្រៃនិងផលប៉ះពាល់ និងត្រូវអនុលោមតាមប្លង់គោលប្រើប្រាស់គម្រោងអភិវឌ្ឍន៍ក្រុងបូកគោចក្ខុវិស័យឆ្នាំ២០៣៥ ដែលរាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យប្រើប្រាស់តាមរយៈអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពត និងខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីបង្ហាញក្បាលដីចំនួន៥ ទីតាំង ទំហំ ១១ ១៧៧ ហិកតា ដែលក្រុមហ៊ុន សុខា អូតែល ស្នើសុំពង្រីកបន្ថែមសម្រាប់គម្រោងអភិវឌ្ឍន៍នៅឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " ស្ថិតនៅភូមិសាស្ត្រ ក្រុងបូកគោ ខេត្តកំពត និងស្រុកព្រៃនប់ ខេត្តព្រះសីហនុ




តារាងនិយាមកាព្រំដី

Projection UTM Zone 48N

Datum WGS 1984

| Name | ID | E | N |
|---|---|---|---|
| A | 1 | 389864.735 | 1183195.306 |
| A | 2 | 392260.947 | 1181297.699 |
| A | 3 | 391884.735 | 1180373.306 |
| A | 4 | 391053.735 | 1179958.306 |
| A | 5 | 388532.735 | 1182293.306 |
| 6 | 6 | 389235.981 | 1184329.155 |
| 7 | 7 | 384176.768 | 1193452.576 |
| 8 | 8 | 389613.410 | 1196862.874 |
| 9 | 9 | 392530.623 | 1191959.066 |
| B | 10 | 390822.164 | 1190259.754 |
| B | 11 | 393373.250 | 1188132.173 |
| B | 12 | 392283.273 | 1186242.590 |
| B | 13 | 388822.871 | 1189128.532 |
| B | 14 | 388380.262 | 1188692.282 |
| B | 15 | 389145.128 | 1186563.969 |
| C | 16 | 382602.735 | 1199366.306 |
| C | 17 | 384252.721 | 1200401.661 |
| C | 18 | 385467.857 | 1199465.168 |
| C | 19 | 386392.786 | 1199538.576 |
| C | 20 | 386727.276 | 1198152.833 |
| C | 21 | 385147.032 | 1197712.458 |
| C | 22 | 384080.441 | 1198598.337 |
| C | 23 | 383552.270 | 1198967.751 |
| D | 24 | 387620.735 | 1212073.306 |
| D | 25 | 387833.321 | 1210465.946 |
| D | 26 | 389246.199 | 1210029.383 |
| D | 27 | 390075.361 | 1210188.921 |
| D | 28 | 390373.326 | 1208640.317 |
| D | 29 | 390525.474 | 1207849.565 |
| D | 30 | 389580.106 | 1206714.658 |
| D | 31 | 388411.078 | 1207416.901 |
| D | 32 | 387868.510 | 1208032.142 |
| D | 33 | 387201.255 | 1209336.309 |
| D | 34 | 387285.632 | 1209735.694 |
| D | 35 | 387094.962 | 1211105.466 |
| D | 36 | 386260.516 | 1212428.578 |
| D | 37 | 386214.068 | 1212823.388 |
| D | 38 | 386423.735 | 1213445.306 |
| E | 39 | 389551.735 | 1212456.306 |
| E | 40 | 389375.735 | 1214355.306 |
| E | 41 | 390652.735 | 1215392.306 |
| E | 42 | 390747.735 | 1215919.306 |
| E | 43 | 389902.735 | 1217291.306 |
| E | 44 | 389867.065 | 1217847.215 |
| E | 45 | 389869.000 | 1217849.291 |
| E | 46 | 389607.782 | 1221896.285 |
| E | 47 | 391340.160 | 1223236.031 |
| E | 48 | 392754.000 | 1222226.000 |
| E | 49 | 393327.000 | 1220808.000 |
| E | 50 | 393164.000 | 1218929.000 |
| E | 51 | 394421.000 | 1217620.000 |
| E | 52 | 393182.694 | 1217189.589 |
| E | 53 | 394411.978 | 1211472.633 |
| E | 54 | 392984.850 | 1210723.901 |
| E | 55 | 391268.722 | 1211710.758 |
| E | 56 | 392721.287 | 1212417.197 |
| E | 57 | 392437.311 | 1214180.837 |
| E | 58 | 392046.599 | 1213909.450 |

ផែនទីនិងតារាងនិយាមកាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី...៤...ខែសីហា..ឆ្នាំ២០២២




តារាងនិយាមកាព្រំដី

Projection UTM Zone 48N

Datum WGS 1984

| Name | ID | E | N |
|---|---|---|---|
| A | 1 | 389864.735 | 1183195.306 |
| A | 2 | 392260.947 | 1181297.699 |
| A | 3 | 391884.735 | 1180373.306 |
| A | 4 | 391053.735 | 1179958.306 |
| A | 5 | 388532.735 | 1182293.306 |
| 6 | 6 | 389235.981 | 1184329.155 |
| 7 | 7 | 384176.768 | 1193452.576 |
| 8 | 8 | 389613.410 | 1196862.874 |
| 9 | 9 | 392530.623 | 1191959.066 |
| B | 10 | 390822.164 | 1190259.754 |
| B | 11 | 393373.250 | 1188132.173 |
| B | 12 | 392283.273 | 1186242.590 |
| B | 13 | 388822.871 | 1189128.532 |
| B | 14 | 388380.262 | 1188692.282 |
| B | 15 | 389145.128 | 1186563.969 |
| C | 16 | 382602.735 | 1199366.306 |
| C | 17 | 384252.721 | 1200401.661 |
| C | 18 | 385467.857 | 1199465.168 |
| C | 19 | 386392.786 | 1199538.576 |
| C | 20 | 386727.276 | 1198152.833 |
| C | 21 | 385147.032 | 1197712.458 |
| C | 22 | 384080.441 | 1198598.337 |
| C | 23 | 383552.270 | 1198967.751 |
| D | 24 | 387620.735 | 1212073.306 |
| D | 25 | 387833.321 | 1210465.946 |
| D | 26 | 389246.199 | 1210029.383 |
| D | 27 | 390075.361 | 1210188.921 |
| D | 28 | 390373.326 | 1208640.317 |
| D | 29 | 390525.474 | 1207849.565 |
| D | 30 | 389580.106 | 1206714.658 |
| D | 31 | 388411.078 | 1207416.901 |
| D | 32 | 387868.510 | 1208032.142 |
| D | 33 | 387201.255 | 1209336.309 |
| D | 34 | 387285.632 | 1209735.694 |
| D | 35 | 387094.962 | 1211105.466 |
| D | 36 | 386260.516 | 1212428.578 |
| D | 37 | 386214.068 | 1212823.388 |
| D | 38 | 386423.735 | 1213445.306 |
| E | 39 | 389551.735 | 1212456.306 |
| E | 40 | 389375.735 | 1214355.306 |
| E | 41 | 390652.735 | 1215392.306 |
| E | 42 | 390747.735 | 1215919.306 |
| E | 43 | 389902.735 | 1217291.306 |
| E | 44 | 389867.065 | 1217847.215 |
| E | 45 | 389869.000 | 1217849.291 |
| E | 46 | 389607.782 | 1221896.285 |
| E | 47 | 391340.160 | 1223236.031 |
| E | 48 | 392754.000 | 1222226.000 |
| E | 49 | 393327.000 | 1220808.000 |
| E | 50 | 393164.000 | 1218929.000 |
| E | 51 | 394421.000 | 1217620.000 |
| E | 52 | 393182.694 | 1217189.589 |
| E | 53 | 394411.978 | 1211472.633 |
| E | 54 | 392984.850 | 1210723.901 |
| E | 55 | 391268.722 | 1211710.758 |
| E | 56 | 392721.287 | 1212417.197 |
| E | 57 | 392437.311 | 1214180.837 |
| E | 58 | 392046.599 | 1213909.450 |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ឆ្វៀលដីទំហំ ១ ហិកតា ៨៦ អា ១៧ សង់ទីអា ស្ថិតនៅស្រុកអូររាំង ខេត្តមណ្ឌលគិរី ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កាត់ឆ្វៀលដីទំហំ ១ ហិកតា ៨៦ អា ១៧ សង់ទីអា ស្ថិតនៅភូមិពូរ៉ាង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដីនិងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រគល់ជូនព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី រណឫទ្ធិ គ្រប់គ្រងជាកម្មសិទ្ធិ។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦០ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# និយ័តកម្មប្រព័ន្ធសន្តិសុខសង្គម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៨៤៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះ កំណត់អំពីគោលការណ៍ វិធាន នីតិវិធី និងយន្តការនៃការធ្វើនិយ័តកម្មដោយនិយ័តករសន្តិសុខសង្គម លើរាល់ប្រតិបត្តិការសន្តិសុខសង្គម ដើម្បីធានាបាននូវស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ។

**មាត្រា២ ._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការសន្តិសុខសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣ ._**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

**១- ប្រធាន អ.ស.ហ** សំដៅដល់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

**២- ទំនាក់ទំនងពិសេស** សំដៅដល់ទំនាក់ទំនងរវាងបុគ្គលដែលជា៖

ក- សហព័ទ្ធ ឬអតីតសហព័ទ្ធ

ខ- ញាតិលោហិតខ្សែផ្ទាល់ក្នុងថ្នាក់ទី៣

គ- សាខាញាតិលោហិតក្នុងថ្នាក់ទី៣

ឃ- សាខាញាតិពន្ធក្នុងថ្នាក់ទី៣

ង- ញាតិខ្សែផ្ទាល់របស់បុគ្គលដែលចូលក្នុងគ្រួសាររបស់បុគ្គលដើមក្នុងនាមជាកូនសុំ និងសហព័ទ្ធរបស់បុគ្គលនោះ

ច- បុគ្គលដែលរស់នៅដោយពឹងផ្អែកលើប្រាក់ ឬទ្រព្យសម្បត្តិ ឬបុគ្គលដែលទទួលរបបអាហារកិច្ចពីបុគ្គលដើម និងបុគ្គលដែលរួមរស់ជាមួយបុគ្គលដើម

**៣- និយោជក** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលសាធារណៈ ឬឯកជនដែលដឹកនាំគ្រប់គ្រង និងប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះជាមិនជាប់លាប់ក្តី ដោយមានផ្តល់ប្រាក់កម្រៃជាទៀងទាត់

**៤- ប្រតិបត្តិការសន្តិសុខសង្គម** សំដៅដល់រាល់សកម្មភាពពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខសង្គម ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដោយរួមបញ្ចូលទាំងសកម្មភាពរបស់តួអង្គ បុគ្គល និង/ឬ ស្ថាប័នពាក់ព័ន្ធ ក្នុងប្រតិបត្តិការសន្តិសុខសង្គមតាមការកំណត់របស់និយ័តករសន្តិសុខសង្គម

**៥- មូលនិធិសន្តិសុខសង្គម** សំដៅដល់បណ្តុំនៃមូលនិធិដែលប្រមូលបានពីការបង់ភាគទានតាមផ្នែកនីមួយៗ នៃរបបសន្តិសុខសង្គម ដែលមានដូចជាមូលនិធិសន្តិសុខសង្គមផ្នែកប្រាក់សោធន មូលនិធិសន្តិសុខសង្គមផ្នែកថែទាំសុខភាព មូលនិធិសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងមូលនិធិសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ

**៦- មូលដ្ឋានសុខាភិបាលឯកជន** សំដៅដល់អង្គភាពព្យាបាលឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយបានចុះកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលជាមួយប្រតិបត្តិករសន្តិសុខសង្គម

**៧- សមាជិកប្រតិបត្តិករសន្តិសុខសង្គម** សំដៅដល់រូបវន្តបុគ្គលដែលទទួលបានភាពជាសមាជិកនៃបេឡាជាតិសន្តិសុខសង្គម ដោយការចុះបញ្ជី និងបាន ឬត្រូវបានបង់ភាគទានក្នុងផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដែលមានកំណត់ក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម

**៨- ស្ថាប័នបញ្ជាក់ចំណាយសេវាសុខាភិបាល** សំដៅដល់ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការបញ្ជាក់ចំណាយទូទាត់ប្រតិបត្តិការសន្តិសុខសង្គម លើរបបថែទាំសុខភាព និងរបបហានិភ័យការងារ ជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករសន្តិសុខសង្គម

**៩- ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ** សំដៅដល់ការសិក្សា វិភាគ និងវាយតម្លៃលើចីរភាពហិរញ្ញវត្ថុ នៃផ្នែកនីមួយៗ នៃរបបសន្តិសុខសង្គម។ រយៈពេលនៃការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ សម្រាប់ផ្នែកប្រាក់សោធនត្រូវធ្វើឡើងយ៉ាងយូរ ៥(ប្រាំ) ឆ្នាំម្តង ផ្នែកហានិភ័យការងារយ៉ាងយូរ ៣(បី) ឆ្នាំម្តង និងផ្នែកថែទាំសុខភាពត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលសរសេរជាអក្សរកាត់ថា **អ.ស.ហ.** ជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ដែលមានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

និយ័តករសន្តិសុខសង្គម ដែលសរសេរជាអក្សរកាត់ថា **ន.ស.ស.** បំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.** លើការងារនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម ដែលមានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវា

ហិរញ្ញវត្ថុមិនមែនធនាគារ និងមាត្រា២១ នៃអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**មាត្រា៥ .-**

**ន.ស.ស.** មានសមត្ថកិច្ចក្នុងការស្នើនូវបទប្បញ្ញត្តិសម្រាប់ការធ្វើនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធជាធរមាន និងអនុក្រឹត្យនេះ ជូនដល់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីអនុម័ត និងដាក់ឱ្យអនុវត្ត។

**ន.ស.ស.** មានសមត្ថកិច្ចត្រួតពិនិត្យប្រតិបត្តិការសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ **ន.ស.ស.** ត្រូវចាត់មន្ត្រីដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ប្រតិបត្តិការ និងឯកសារពាក់ព័ន្ធនានារបស់ប្រតិបត្តិករសន្តិសុខសង្គម មូលដ្ឋានសុខាភិបាលឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករសន្តិសុខសង្គម តួអង្គ បុគ្គល និង/ឬ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្នុងប្រតិបត្តិការសន្តិសុខសង្គម។ ប្រតិបត្តិករសន្តិសុខសង្គម មូលដ្ឋានសុខាភិបាលឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករសន្តិសុខសង្គម តួអង្គ បុគ្គល និង/ឬ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្នុងប្រតិបត្តិការសន្តិសុខសង្គម មានកាតព្វកិច្ចផ្ដល់របាយការណ៍និងឯកសារតាមការស្នើសុំរបស់មន្ត្រី **ន.ស.ស.** ដើម្បីបំពេញការងារនិយ័តកម្ម។

**មាត្រា៦ .-**

បេឡាជាតិសន្តិសុខសង្គមដែលសរសេរជាអក្សរកាត់ថា **ប.ស.ស.** គឺជាប្រតិបត្តិករសន្តិសុខសង្គម ដែល **ន.ស.ស.** មានសមត្ថកិច្ចធ្វើនិយ័តកម្មដូចមានចែងក្នុងច្បាប់ស្ដីពីរបបសន្តិសុខសង្គម អនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត។

## ជំពូកទី៣
## ការត្រួតពិនិត្យប្រតិបត្តិការក្នុងប្រព័ន្ធសន្តិសុខសង្គម និងកាតព្វកិច្ចផ្ដល់របាយការណ៍

**មាត្រា៧ .-**

ការត្រួតពិនិត្យប្រតិបត្តិការសន្តិសុខសង្គមដោយ **ន.ស.ស.** ត្រូវអនុវត្តផ្អែកលើផែនការត្រួតពិនិត្យ និងសៀវភៅណែនាំ ស្ដីពីការត្រួតពិនិត្យដែលទទួលបានការសម្រេចពីប្រធាន **អ.ស.ហ.**។

**មាត្រា៨ .-**

**ប.ស.ស.** ត្រូវរៀបចំ និងដាក់ជូន **ន.ស.ស.** នូវផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់ឆ្នាំបន្ទាប់ យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែឧសភា។

**មាត្រា៩ .-**

**ប.ស.ស.** ត្រូវរៀបចំ និងដាក់ជូន **ន.ស.ស.** នូវយន្តការគ្រប់គ្រងហានិភ័យ និងដោះស្រាយបញ្ហាគ្រាមានអាសន្ន ដើម្បីបង្ការ បញ្ចៀស ឬកាត់បន្ថយអានុភាពហានិភ័យ ដែលអាចកើតមានឡើងពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួន និងត្រូវដាក់ជូន **ន.ស.ស.** យ៉ាងយូរ

ត្រឹមថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ ទម្រង់ និងធាតុអប្បបរមានៃយន្តការគ្រប់គ្រងហានិភ័យ និងដោះស្រាយបញ្ហាគ្រាមានអាសន្ន ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

**មាត្រា១០ ._**

**ប.ស.ស.** ត្រូវធ្វើការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ ដើម្បីធានានូវចីរភាពហិរញ្ញវត្ថុលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម អនុលោមតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន និងត្រូវដាក់ជូន **ឧ.ស.ស.** នូវលទ្ធផលនៃការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ បន្ទាប់ពីបញ្ចប់ការគណនា។

**មាត្រា១១ ._**

**ប.ស.ស.** ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការិយបរិច្ឆេទគណនេយ្យនីមួយៗរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ។

**ប.ស.ស.** ត្រូវជ្រើសរើសក្រុមហ៊ុនសវនកម្មដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករគណនេយ្យ និងសវនកម្ម ដោយអនុលោមតាមលក្ខខណ្ឌ និងនីតិវិធីក្នុងការជ្រើសរើសដែលកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **អ.ស.ហ.** មុនពេលដំណើរការសវនកម្ម។

**មាត្រា១២ ._**

**ប.ស.ស.** ត្រូវផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអំពីស្ថានភាព នៃរបបសន្តិសុខសង្គមតាមផ្នែកនីមួយៗ ដោយអនុលោមទៅតាមគោលការណ៍ណែនាំស្ដីពីការផ្សព្វផ្សាយព័ត៌មាននៃប្រព័ន្ធសន្តិសុខសង្គម ដែលកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

**មាត្រា១៣ ._**

**ប.ស.ស.** ត្រូវរៀបចំបង្កើតថ្នាលបច្ចេកវិទ្យាព័ត៌មានដែលអនុញ្ញាតឱ្យសមាជិកទទួលបានព័ត៌មាន ស្ដីពីសិទ្ធិក្នុងការទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមតាមផ្នែកនីមួយៗ។

**មាត្រា១៤ ._**

**ប.ស.ស.** ត្រូវឃ្លាំមើលនូវភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃប្រតិបត្តិការសន្តិសុខសង្គមតាមផ្នែកនីមួយៗ។

លក្ខណៈវិនិច្ឆ័យនៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃប្រតិបត្តិការសន្តិសុខសង្គមតាមផ្នែកនីមួយៗ រួមទាំងមូលនិធិវិនិយោគត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

**មាត្រា១៥ ._**

**ប.ស.ស.** ត្រូវផ្ដល់របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងរបាយការណ៍ផ្សេងទៀតជូន **ឧ.ស.ស.**។

ប្រភេទ និងទម្រង់នៃរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងរបាយការណ៍ផ្សេងទៀត ត្រូវកំណត់ដោយសេចក្ដីណែនាំរបស់ **ឧ.ស.ស.**។

**មាត្រា១៦ .-**

**ប.ស.ស.** ត្រូវផ្តល់របាយការណ៍ និងព័ត៌មានដូចមានចែងក្នុងអនុក្រឹត្យនេះ ជូន **ន.ស.ស.** ជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយផ្សេងទៀត ដែលកំណត់ដោយ **ន.ស.ស.**។

**មាត្រា១៧ .-**

**ប.ស.ស.** ត្រូវបង់កម្រៃសេវាត្រួតពិនិត្យជូន **ន.ស.ស.**។ អត្រា នីតិវិធីនៃការបង់ និងការចាត់ចែងកម្រៃសេវាត្រួតពិនិត្យ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី៤
## និយ័តកម្មលើការប្រើប្រាស់សេវារបស់មូលដ្ឋានសុខាភិបាល

**មាត្រា១៨ .-**

ការទូទាត់ចំណាយសេវាសុខាភិបាល ជូនមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** ត្រូវឆ្លងកាត់ការពិនិត្យ និងបញ្ជាក់សំណើទូទាត់ជាមុនដោយស្ថាប័នបញ្ជាក់ចំណាយសេវាសុខាភិបាល ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់រាជរដ្ឋាភិបាល។

**មាត្រា១៩ .-**

ស្ថាប័នបញ្ជាក់ចំណាយសេវាសុខាភិបាល មានកាតព្វកិច្ចផ្តល់របាយការណ៍ស្តីពីការពិនិត្យ និងបញ្ជាក់សំណើទូទាត់ជូន **ន.ស.ស.**។ ប្រភេទ និងទម្រង់ នៃរបាយការណ៍ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ **ន.ស.ស.**។

**មាត្រា២០ .-**

**ប.ស.ស.** ត្រូវស្នើសុំការឯកភាពជាមុនពី **ន.ស.ស.** មុននឹងចុះកិច្ចព្រមព្រៀងប្រើប្រាស់សេវាសុខាភិបាល កែសម្រួល ឬបញ្ចប់កិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជន និងត្រូវផ្តល់ជូន **ន.ស.ស.** នូវកិច្ចព្រមព្រៀងដែលបានចុះរួច និងឯកសារពាក់ព័ន្ធផ្សេងទៀត។

**ប.ស.ស.** ត្រូវធានាថារាល់ការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាលជាមួយមូលដ្ឋានសុខាភិបាលឯកជន អនុវត្តទៅប្រកបដោយតម្លាភាព និងជៀសវាងទំនាស់ផលប្រយោជន៍។

លក្ខខណ្ឌតម្រូវសម្រាប់ **ប.ស.ស.** ក្នុងការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាល ជាមួយមូលដ្ឋានសុខាភិបាលឯកជន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

**មាត្រា២១ .-**

ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់ របស់ **ប.ស.ស.** មិនត្រូវមានទំនាក់ទំនងពិសេសជាមួយមូលដ្ឋានសុខាភិបាលឯកជន ដែលត្រូវចុះកិច្ចព្រមព្រៀងប្រើប្រាស់សេវាសុខាភិបាលជាមួយ **ប.ស.ស.** ជាដាច់ខាត។

## ជំពូកទី៥
## និយ័តកម្មលើការវិនិយោគមូលនិធិសន្តិសុខសង្គម

**មាត្រា២២ .-**

ការវិនិយោគមូលនិធិសន្តិសុខសង្គម ត្រូវគោរពតាមគោលការណ៍ប្រុងប្រយ័ត្ន រួមមានការរក្សាសុវត្ថិភាពមូលនិធិវិនិយោគ ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងផលចំណូលនៃការវិនិយោគមូលនិធិ។

ការវិនិយោគមូលនិធិសន្តិសុខសង្គម ត្រូវអនុលោមតាមគោលការណ៍ណែនាំ ស្តីពីការវិនិយោគមូលនិធិសន្តិសុខសង្គម។ យន្តការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម និងគោលការណ៍ណែនាំ ស្តីពីការវិនិយោគមូលនិធិសន្តិសុខសង្គម ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី៦
## ការដោះស្រាយវិវាទ

**មាត្រា២៣ .-**

វិវាទ ឬបណ្តឹងពាក់ព័ន្ធនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គម រវាងសមាជិក **ប.ស.ស.** និយោជក និង **ប.ស.ស.** ត្រូវដោះស្រាយដោយគណៈកម្មការដោះស្រាយវិវាទនៃ **ប.ស.ស.**។ ក្នុងករណីមិនសះជា វិវាទ ឬបណ្តឹងនោះ អាចត្រូវបានប្តឹងទៅ **ន.ស.ស.** មុននឹងប្តឹងទៅតុលាការមានសមត្ថកិច្ច។

នីតិវិធី និងយន្តការនៃការដោះស្រាយវិវាទ ឬបណ្តឹងដោយ **ន.ស.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី៧
## ទណ្ឌកម្ម

**មាត្រា២៤ .-**

បុគ្គល និងតួអង្គពាក់ព័ន្ធដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យ និងទោស ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១ កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥០៧ អនក្រ.តត**

# អនុក្រឹត្យ

**ស្តីពី**

**ការតែងតាំងមុខតំណែង នាយទាហាន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** តែងតាំងមុខតំណែង នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនឧត្តមសេនីយ៍ទោ **ហង្ស សុវណ្ណរដ្ឋ** អត្តលេខ ០៤៣០៧១ ជា នាយក នាយកដ្ឋានយានយន្ត អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ជំនួស ឧត្តមសេនីយ៍ទោ **គង់ វ៉ាន់នរិទ្ធ** ទទួលភារកិច្ចថ្មី ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១៣ កើត ខែ អាសាឍ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **មួង ប៉ាង** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ជាអភិបាលរង នៃគណៈអភិបាលខេត្តរតនគិរី សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៣ កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងមន្ត្រីរាជការ ដូចមានរាយនាមខាងក្រោមៈ

១- លោក **ជុន សុវណ្ណារិទ្ធ** បច្ចុប្បន្នប្រធាននាយកដ្ឋានទំនាក់ទំនងដៃគូសន្ទនាអាស៊ាន ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន

២- លោកស្រី **គាន់ សូលីតា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានទំនាក់ទំនងដៃគូសន្ទនាអាស៊ាន ជាប្រធាននាយកដ្ឋានទំនាក់ទំនងដៃគូសន្ទនាអាស៊ាន

៣- លោក **ជ សំផល** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានសហប្រតិបត្តិការមេគង្គ ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៩រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ២០៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារ៉ាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១.**_ បំពាក់មេដាយ **មុនីសារ៉ាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនពលរដ្ឋខ្មែរនៅប្រទេសបែលហ្ស៊ិក និងហូឡង់ ចំនួន ១១នាក់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់កិត្យានុភាពជាតិ អភិរក្សវប្បធម៌ និងអរិយធម៌ខ្មែរ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោមៈ

| | |
|---|---|
| ១. លោក តាន់ ជាតអួន | ៧. លោក ឱត វណ្ណាវុទ្ធ |
| ២. លោក ជាប ទូច | ៨. លោក តាន់ ឆាន់នីន |
| ៣. លោកស្រី យ៉ង់ វន | ៩. លោក ផៃ គឹមថង |
| ៤. លោក ពិង គឹមស៊ុនលី | ១០. លោក ឈុន សិរីសុត្ថា |
| ៥. លោក អ៊ុច សាវិន | ១១. លោក លូ គ្មាន់ធិញ។ |
| ៦. លោក សែម ប៊ិន | |

**មាត្រា ២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០២២
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥០៨.អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្ត និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១ .-** ដាក់លោក **ឃុត ឈន** បានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឱ្យចូលនិវត្តន៍មុនអាយុកំណត់ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី **៣១ ខែ មីនា ឆ្នាំ ២០២២**។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៣ កើត ខែ អាសាឍ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:៥០៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំងលោក **ណុច សាវ៉ាន់** ជាអធិការ នៃអគ្គាធិការដ្ឋាន នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៣ កើត ខែ អាសាឍ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៩០៦.អនក្រ.តត.

## អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន ៤៧២ រូប នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១-លោក អ៊ុច និមល | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២-លោក ហ៊ូ សុបុល | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣-លោក ញ៉ែម សុផន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤-លោក អ៊ុច យ៉ាសាធ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៥-លោក វ៉ាន់ មុនីរ័ត្ន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៦-លោក ខាន់ សំភាស់ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |

| | |
|---|---|
| ៧-លោក ឡុង ឌឹម | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៨-លោក សាំង សុផល | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៩-លោក ហូវ សុឃុន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១០-លោក ទូន សុខា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១១-លោក នងលន់ ធនវឌ្ឍន៍ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១២-លោក យឹម រ៉ុន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១៣-លោក ហួត គៀង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១៤-លោក សួង ហុង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១៥-លោក ឱុច សារ៉ាប៊ុនចាន់ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១៦-លោក យ៉ាន់ សឿប | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១៧-លោក ញ៉ឹប ប៊ុនធឿន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១៨-លោក គ្រួច សារ៉េត | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ១៩-លោក ទ្រិញ កាន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២០-លោក ឡេង សារី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២១-លោក ហង់ គឹមឈាន់ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២២-លោក ឈិត សាវុធ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២៣-លោក អ៊ិន ផល្លាក់ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២៤-លោក មុត ភន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២៥-លោក ស៊ឹម សុភាព | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២៦-លោក ជឿន ភ័ក្រ្ត | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២៧-លោក លន លីណា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២៨-លោក ឆែម តារា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ២៩-លោក ខូវ ណារិន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣០-លោក យូ រ៉ាដា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣១-លោក លី ណារិទ្ធ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣២-លោក កង សុខជា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣៣-លោក អ៊ុច ផលរដ្ឋ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣៤-លោក ព្រំ សម្ផស្ស | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣៥-លោក សុខ ចំណាន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣៦-លោក យ៉ែម ណៃតណាទិត្យ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣៧-លោក ម៉េង គាង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣៨-លោក ឡាច សារ៉ន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៣៩-លោក អ៊ិច រ៉ាន្នី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤០-លោក ចេង សារ៉េត | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤១-លោក ប៊ិន តុលា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤២-លោក ជឹន និមល | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |

| | |
|---|---|
| ៤៣-លោក ហុង ពិដោរ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤៤-លោក ជា វិបុល | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤៥-លោក ខោល សារ៉ាន់ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤៦-លោក តាំង សុភា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤៧-លោក ហែម ស៊ីនុជ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤៨-លោក ហម ហ៊ាន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៤៩-លោក សយ សារ៉ាន់ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៥០-លោក ទេស សុនកិរុណ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៥១-លោក ស៊ាន វិចិត្រ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៥២-លោក ថៅ ឧស្សាហ៍ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៥៣-លោក ចក់ ពេជ្រសង្ហា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៥៤-លោក ឈិន តៃឈាង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៥៥-លោក អេង កុយ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
| ៥៦-លោក គង់ វុទ្ធី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជា ថ្នាក់លេខ ១ |
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ស្តីពីការបង្កើតសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ ចំនួន ០៧រូប ដូចមានរាយនាមខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម **ឃួង ស្រេង** | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | ប្រធាន |
| ២-ឯកឧត្តម **ឈាង វណ្ណារិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ៣-លោក **មួន ហេង** | ប្រធាននាយកដ្ឋានមុខងារ និងធនធាន នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៤-លោក **ប៉ាក សុខារ៉ាឌុត** | អគ្គនាយករងស្តីទី នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |
| ៥-លោក **តូច សុវណ្ណារ៉ា** | ប្រធាននាយកដ្ឋានថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត នៃអគ្គនាយកដ្ឋានថាមពល ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៦-លោក **គីម សេត** | អគ្គនាយក នៃសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ | សមាជិក |
| ៧-លោក **សំ សាមុត** | តំណាងបុគ្គលិក នៃសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ | សមាជិក។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៣ កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥២១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១.**.បំពាក់មេដាយ**ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ៥១រូប នៃខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមាននាមខាងក្រោម៖

ក-មេដាយ**មាសការងារ**

| | |
|---|---|
| ១-លោកស្រី ជិប សាវត្តី | មន្ត្រីសាលាក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ |
| ២-លោក គី សុភាព៉ា | ស្មៀនឃុំស្រះរាំង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ |

ខ-មេដាយ**ប្រាក់ការងារ**

| | |
|---|---|
| ១-លោកស្រី យឿន វណ្ណវតី | ប្រធានការិយាល័យសាលាស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ |
| ២-លោក ហ៊ាង សុភិម | អនុប្រធានការិយាល័យសាលាខេត្តបន្ទាយមានជ័យ |
| ៣-លោកស្រី ម៉ុប ឆវី | អនុប្រធានការិយាល័យសាលាខេត្តបន្ទាយមានជ័យ |
| ៤-លោក វ៉ាន់ ប៊ុនធី | អនុប្រធានការិយាល័យសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ |
| ៥-លោកស្រី ឃ្លោក រិតថន | អនុប្រធានការិយាល័យសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ |

៦-លោកស្រី ពេទ្យ ស្រីនិច មន្ត្រីអង្គភាពច្រកចេញចូលតែមួយសាលាខេត្តបន្ទាយមានជ័យ
៧-លោក ពេជ្រ ដារ៉ា មន្ត្រីសាលាខេត្តបន្ទាយមានជ័យ
៨-លោក សឿម ពិសិត មន្ត្រីសាលាខេត្តបន្ទាយមានជ័យ
៩-លោកស្រី ទៀង វិញ្ញា មន្ត្រីសាលាខេត្តបន្ទាយមានជ័យ
១០-លោក អ៊ា លឹមចក់ មន្ត្រីសាលាក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
១១-លោកស្រី សុខ ភូមារ៉ា មន្ត្រីសាលាស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ
១២-លោកស្រី លី ហួរ ស្មៀនឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

គ-មេដាយ**សំរឹទ្ធអាវរ**

១-លោក ស៊ិន ប៊ុនស៊ីវ អភិបាលរងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
២-លោកស្រី ជុំ រស្មី អភិបាលរងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
៣-លោកស្រី សុវណ្ណ សៅបូរី អនុប្រធានការិយាល័យសាលាខេត្តបន្ទាយមានជ័យ
៤-លោក តាន់ សុផល ប្រធានការិយាល័យសាលាខេត្តបន្ទាយមានជ័យ
៥-លោក ភួន ឡាំហ៊ិញ នាយករងរដ្ឋបាលសាលាស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ
៦-លោក គី មិនា ប្រធានការិយាល័យសាលាស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ
៧-លោក អេង សំអាត ប្រធានការិយាល័យសាលាស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
៨-លោកស្រី ឈួន កាន់យ៉ា ប្រធានការិយាល័យសាលាស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ
៩-លោក ហៃ ឃោសា ប្រធានការិយាល័យសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
១០-លោក ជិន សូផាន ប្រធានការិយាល័យសាលាស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
១១-លោក ឈឹម ចាន់សេដ្ឋា អនុប្រធានការិយាល័យសាលាស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ
១២-លោក ហ៊ិន សុហេង អនុប្រធានការិយាល័យសាលាស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ
១៣-លោក ភើយ សុខភិត អនុប្រធានការិយាល័យសាលាស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ
១៤-លោក ភឿ ពន្លក អនុប្រធានការិយាល័យសាលាស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ
១៥-លោកស្រី ឈឿ កញ្ញា អនុប្រធានការិយាល័យសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
១៦-លោក ហ៊ី សារ៉ាត់ អនុប្រធានការិយាល័យសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
១៧-លោក សល់ ជុង អនុប្រធានការិយាល័យសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
១៨-លោកស្រី ស្រិល ម៉ាល័យ អនុប្រធានការិយាល័យសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
១៩-លោក លេន សុវណ្ណា អនុប្រធានការិយាល័យសាលាស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
២០-លោកស្រី ងួត ស្រីដួត អនុប្រធានការិយាល័យសាលាស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
២១-លោកស្រី ភួង ថារិន អនុប្រធានការិយាល័យសាលាស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

២២-លោក ហួត ខៃឆុង អនុប្រធានការិយាល័យសាលាស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

២៣-លោក ជាវ វែង អនុប្រធានការិយាល័យសាលាស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

២៤-លោក ជុំ វណ្ណា អនុប្រធានការិយាល័យសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

២៥-លោកស្រី គឹម ហៀក អនុប្រធានការិយាល័យសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

២៦-លោក វៀក ចន្ទ្រី អនុប្រធានការិយាល័យសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

២៧-លោកស្រី ប៉ែន គឹមហួ មន្ត្រីសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

២៨-លោកស្រី ផាន សុភ័ក្រ្ត មន្ត្រីសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

២៩-លោក ប្លុង សៅគន្ធ មន្ត្រីសាលាក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

៣០-លោកស្រី រឿង នារីហ៊ាប មន្ត្រីសាលាក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

៣១-លោកស្រី សរ គឹមសួរ មន្ត្រីសាលាក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

៣២-លោក អ៊ឹង ម៉េងគាង មន្ត្រីសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

៣៣-លោកស្រី ស្មឿន រ័ត្នមន្នី មន្ត្រីសាលាស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៣៤-លោកស្រី គង់ ម៉ាលី ស្មៀនឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៣៥-លោក យ៉ៃ ឡាក់ម៉ានី មន្ត្រីសាលាស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

៣៦-លោក អ៊ុំ ពៀន មន្ត្រីសាលាស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

៣៧-លោកស្រី ថេង ស្រីវួន មន្ត្រីសាលាស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៥ កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីពិនិត្យផ្លូវច្បាប់ លើកិច្ចព្រមព្រៀងដែលកំពុងអនុវត្ត ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មី សម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១._**

ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីពិនិត្យផ្លូវច្បាប់លើកិច្ចព្រមព្រៀងដែលកំពុងអនុវត្ត ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មីសម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងខេត្តព្រះសីហនុ ហៅកាត់ថា "គណៈកម្មាធិការអន្តរក្រសួង" ដែលមានសមាសភាព ដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **ជា សុផារ៉ា** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២. ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធានប្រចាំការ |
| ៣. ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៤. ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៥. ឯកឧត្តម **ខី តាឃី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. ឯកឧត្តម **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៧. ឯកឧត្តម **សយ សុខាន់** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៨. ឯកឧត្តម **លី រស្មី** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩. ឯកឧត្តម **ហូ លីហួរ** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១០. ឯកឧត្តម **ពេជ អន្ត** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១. ឯកឧត្តម **ហាក់ សុខហេង** | សមាជិកនិងជាអគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១២. ឯកឧត្តម **ព្រូ ស៊ីថន** | ទីប្រឹក្សារដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៣. ឯកឧត្តម **ឃួង ស្រេង** | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១៤. ឯកឧត្តម **គួច ចំរើន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ១៥. ឯកឧត្តម **ទៀ សីហា** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ១៦. ឯកឧត្តម **សារិន គុណ្ណាករ** | អគ្គនាយកបច្ចេកទេស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក/លេខាធិការ |
| ១៧. ឯកឧត្តម **សៅ វឌ្ឍនា** | នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | សមាជិក |
| ១៨. ឯកឧត្តម **ម៉ិន រដ្ឋា** | នាយកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប | សមាជិក |
| ១៩. ឯកឧត្តម **វ៉ាន់ ណូរ៉ាក់** | នាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ | សមាជិក |
| ២០. លោកបណ្ឌិត **សរ សិនិរ៉ា** | ប្រធាននាយកដ្ឋាននីតិកម្មនិងច្បាប់វិនិយោគ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២១. លោក **ឡុង ហៃអំពូល** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | លេខាធិការ |

**ប្រការ ២.**_

គណៈកម្មាធិការអន្តរក្រសួងមានភារៈកិច្ច ដូចខាងក្រោម៖

- ពិនិត្យនិងសិក្សាកិច្ចព្រមព្រៀងសម្បទាន ដែលមានស្រាប់ទាំងអស់ពាក់ព័ន្ធនឹងការវិនិយោគអាកាសយានដ្ឋានអន្តរជាតិនៅភ្នំពេញនិងខេត្តព្រះសីហនុ រវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) និងជាមួយក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មី។
- ពិនិត្យបញ្ចប់កិច្ចព្រមព្រៀង រវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ដើម្បីដំណើរការក្រុមហ៊ុនវិនិយោគថ្មី(AIAI)។

- ពិនិត្យនិងចរចាជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) និងក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) ដើម្បីរៀបចំកិច្ចព្រមព្រៀងសហប្រតិបត្តិការវិនិយោគលើអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី និងបិទអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបច្ចុប្បន្ន។
- ពិនិត្យនិងចរចាជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មីសម្រាប់អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ដោយដាក់បញ្ចូលនូវគម្រោងផែនការនិងពេលវេលាអភិវឌ្ឍថ្មី។
- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពក្នុងការពិនិត្យនិងរៀបចំកិច្ចព្រមព្រៀងថ្មីសម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុជូន ប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យសម្រេចនិងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣._**

គណៈកម្មាធិការអន្តរក្រសួង មានសិទ្ធបង្កើតអនុគណៈកម្មាធិការឬក្រុមការងារមួយចំនួនតាមការចាំបាច់ដោយសេចក្តីសម្រេចរបស់ប្រធាន។

**ប្រការ ៤._**

គណៈកម្មាធិការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ ៥._**

គណៈកម្មាធិការអន្តរក្រសួង អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអ្នកជំនាញ ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងផ្តល់យោបល់តាមការចាំបាច់។

**ប្រការ ៦._**

គណៈកម្មាធិការអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ ៧._**

ប្រភពថវិកាចំណាយរបស់គណៈកម្មាធិការអន្តរក្រសួង គឺបានមកពីប្រភព៖

- ថវិកាជាតិក្នុងគម្រោងចំណាយរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ការឧបត្ថម្ភពីក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) និងក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ (AIAI)។

**ប្រការ ៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារៈកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១២កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:..[illegible]..../សហវ.[illegible]......

SOCIAL PROTECTION IN CAMBODIA

**សេចក្តីសម្រេច**
**ស្តីពី**
**ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ**
**ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី ១១**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/២៤១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ០៤៤ សហវ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ស្តីពីកាលបរិច្ឆេទនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចលេខ ០៥៨ សហវ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី២
- បានឃើញសេចក្តីសម្រេចលេខ ០៦៦ សហវ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៣

- បានឃើញសេចក្តីសម្រេចលេខ ០៨១ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៤
- បានឃើញសេចក្តីសម្រេចលេខ ០១២ សហវ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៥
- បានឃើញសេចក្តីសម្រេចលេខ ០៣៦ សហវ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៦
- បានឃើញសេចក្តីសម្រេចលេខ ០៥០ សហវ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៧
- បានឃើញសេចក្តីសម្រេចលេខ ០០៥ សហវ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៨
- បានឃើញសេចក្តីសម្រេចលេខ ០៧៧ សហវ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៩
- បានឃើញសេចក្តីសម្រេចលេខ ០៩៥ សហវ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី១០
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

**ប្រការ១.-**

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបន្តអនុវត្តសម្រាប់ជុំទី១១ ដែលមានរយៈពេល ៣ (បី) ខែ គឺខែតុលា ខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២២។

រយៈពេលអនុវត្តបន្ត នឹងត្រូវកំណត់ដោយឡែក ផ្អែកតាមសភាពការណ៍វិវត្តន៍ជាក់ស្តែង។

**ប្រការ២.-**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភ ត្រូវធ្វើឡើងក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ។

**ប្រការ៣.-**

អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧ រោច ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.៦៩៦.....សហវ.....ប្រក

**ប្រកាស**
**ស្តីពី**
**ការបង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម និងគណៈកម្មការវាយតម្លៃជ្រើសរើសទីប្រឹក្សា ដើម្បីរៀបចំបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញប្រកាសលេខ ៤៨៧ សហវ-ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការវិនិយោគសាធារណៈ
- បានឃើញប្រកាសលេខ ២៥៣ សហវ-ប្រក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

បង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម និងគណៈកម្មការវាយតម្លៃជ្រើសរើសទីប្រឹក្សាសម្រាប់÷

- ជ្រើសរើស និងរៀបចំបញ្ជីក្រុមហ៊ុនទីប្រឹក្សា ដើម្បីផ្តល់សេវាទីប្រឹក្សាគាំទ្រដល់ការរៀបចំអភិវឌ្ឍ និងការអនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (ភ.រ.ជ.)។
- ជ្រើសរើសទីប្រឹក្សាផ្សេងទៀតដើម្បីគាំទ្រដល់ការត្រួតពិនិត្យ និងវាយតម្លៃលើការសិក្សាសមិទ្ធិលទ្ធភាពគម្រោង ភ.រ.ជ.។

**ប្រការ២ .–**

តែងតាំងសមាសភាពគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម និងគណៈកម្មការវាយតម្លៃជ្រើសរើសទីប្រឹក្សា ដូចខាងក្រោម÷

**ក. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម**

| | | | |
|---|---|---|---|
| ១- លោក | **ហេង ទុន្និកា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន (អ.រ.ជ.) | ជាប្រធាន |
| ២- លោកស្រី | **តាន់ ឡានីន** | ប្រធាននាយកដ្ឋានប្រគល់ និងត្រួតពិនិត្យគម្រោង នៃ អ.រ.ជ. | ជាសមាជិក |
| ៣- តំណាងលេខាធិការដ្ឋាន នៃគណៈកម្មការវិនិយោគសាធារណៈ | | | ជាសមាជិក |

គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម មានភារកិច្ច÷

- ពិនិត្យ និងសម្រេចលើឯកសារស្នើសុំបញ្ជាក់ពីចំណាប់អារម្មណ៍ (REOI) ដែលរៀបចំដោយគណៈកម្មការវាយតម្លៃជ្រើសរើសទីប្រឹក្សា។
- ពិនិត្យ និងសម្រេចលើរបាយការណ៍វាយតម្លៃឯកសារបញ្ជាក់ពីចំណាប់អារម្មណ៍ (EOI) នៃក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹក្សាផ្សេងទៀត របស់គណៈកម្មការវាយតម្លៃជ្រើសរើសទីប្រឹក្សា។
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំបញ្ជីក្រុមហ៊ុនទីប្រឹក្សា ឬការជ្រើសរើសទីប្រឹក្សាផ្សេងទៀត ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័ត។

**ខ. គណៈកម្មការវាយតម្លៃជ្រើសរើសទីប្រឹក្សា**

| | | | |
|---|---|---|---|
| ១- លោក | **ឈឹម សុចស្នើ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍គម្រោង នៃ អ.រ.ជ. | ជាប្រធាន |
| ២- លោក | **អ៊ិន សាភាន** | ប្រធានការិយាល័យអភិវឌ្ឍន៍គម្រោង នៃនាយកដ្ឋានអភិវឌ្ឍន៍គម្រោង | ជាសមាជិក |
| ៣- លោកស្រី | **មុត ច័ន្ទម៉ានិត** | ប្រធានការិយាល័យមូលនិធិអភិវឌ្ឍន៍គម្រោង នៃនាយកដ្ឋានអភិវឌ្ឍន៍គម្រោង | ជាសមាជិក |

គណៈកម្មការវាយតម្លៃជ្រើសរើសទីប្រឹក្សា មានភារកិច្ច÷

- រៀបចំឯកសារស្នើសុំបញ្ជាក់ពីចំណាប់អារម្មណ៍ដើម្បីផ្សព្វផ្សាយដល់ក្រុមហ៊ុនទីប្រឹក្សា និងទីប្រឹក្សាផ្សេងទៀតឱ្យចូលរួមការដេញថ្លៃ។
- ពិនិត្យ និងវាយតម្លៃលើឯកសារបញ្ជាក់ពីចំណាប់អារម្មណ៍របស់ក្រុមហ៊ុនទីប្រឹក្សា និងទីប្រឹក្សាផ្សេងទៀតដែលបានដាក់ចូលរួមដេញថ្លៃ។
- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការពិនិត្យ និងវាយតម្លៃឯកសារបញ្ជាក់ពីចំណាប់អារម្មណ៍សម្រាប់ដាក់ជូនគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម ដើម្បីពិនិត្យ និងសម្រេច។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៨ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២ និងប្រការ៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០១១......សហវ.......

# សារាចរ
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី២ ជំហានទី២ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

អនុវត្តតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) និងបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងដំណាក់កាលទី១ មាន ៣ជំហាន នៅរដ្ឋបាលកណ្តាល សម្រាប់ក្រសួង ស្ថាប័ន ចំនួន២៣ និងមន្ទីរ អង្គភាពជំនាញចំនួន ១៨ នៅរាជធានី ខេត្ត និងក្នុងដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ រួចមកហើយ។

នៅក្នុងដំណាក់កាលទី២ ជំហានទី២ នេះ ប្រព័ន្ធ NRMIS នឹងដាក់ឱ្យអនុវត្តដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះ រដ្ឋបាលខណ្ឌទាំងអស់នៃរាជធានីភ្នំពេញ នឹងចាប់អនុវត្តពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ និងរដ្ឋបាលក្រុង ស្រុក នៅទូទាំងប្រទេស នឹងចាប់អនុវត្តពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ តទៅ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តដាក់ឱ្យអនុវត្តប្រព័ន្ធ NRMIS ដល់រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត នៅក្នុងដំណាក់កាលនិងជំហានបន្តបន្ទាប់។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវប្រើប្រាស់លេខកូដបង់ចំណូលមិនមែនសារពើពន្ធដែលបានកំណត់ ដោយលម្អិតតាមចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត។ គ្រប់ចំណូលមិនមែនសារពើពន្ធទាំងអស់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលអាចប្រមូលនិងបង់ចូលថវិកាថ្នាក់ក្រោមជាតិ (ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ) បានលុះត្រាតែមានលេខកូដបង់ចំណូលដែលអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ ឬ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) ដែលស្នើដោយអគ្គនាយកដ្ឋានរដ្ឋបាល ឬ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ។ បញ្ជីលេខកូដចំណូលមិនមែនសារពើពន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗ ជាឧបសម្ព័ន្ធនៃសារាចរនេះ។

ដើម្បីមានមូលដ្ឋានក្នុងការប្រើប្រាស់វិក្កយបត្រដែលមានលេខកូដបង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត) សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចដាក់ចេញនូវសេចក្តីណែនាំអំពីនីតិវិធីនៃការប្រមូលនិងការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS និងបង់ចំណូលទៅធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ដូចខាងក្រោម÷

១.ការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS÷ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រោយពីទទួលបានចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត ត្រូវកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS។

២.ពេលបង់ចំណូលទៅធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

-ចំពោះចំណូលពីសេវាសាធារណៈ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ចំនួន០២ច្បាប់ ដោយ ០១ច្បាប់រក្សាទុកជូនធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ និង ០១ច្បាប់ទៀត រក្សាទុកដោយរជ្ជទេយ្យករចំណូលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី ដើម្បីភ្ជាប់ជាមួយសាច់ប្រាក់ដែលត្រូវបង់ ឬ បង្វែរចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ

-ចំពោះចំណូលពីទ្រព្យសម្បត្តិរដ្ឋ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ជូនអតិថិជនដើម្បីបង់ប្រាក់នៅធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ

-ចំពោះចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចអនុវត្តតាមនីតិវិធីនៃការបង់ចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋតាមយថាប្រភេទនៃចំណូលជាក់ស្តែង។

-ក្រោយពីបានបង់ប្រាក់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកត់ត្រាលេខយោងលើបណ្ណបង់ប្រាក់ (Bank Slip) ឬ ប្រកាសឥណពន្ធ (Debit Advice) ឬ បណ្ណផ្ទេរប្រាក់/ឥណទាន (Remittance Slip) ចូលក្នុងប្រព័ន្ធ NRMIS ដើម្បីបញ្ចប់ប្រតិបត្តិការ នៃវិក្កយបត្រ (ក្នុងករណីជាប្រាក់ដុល្លារអាមេរិក អត្រាប្តូរប្រាក់នឹងត្រូវកំណត់តាមធនាគារជាតិនៃកម្ពុជា)។

៣. ការបង្វែរចំណូលទៅថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ÷

-ប្រព័ន្ធ NRMIS នឹងធ្វើការបង្កើតសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយស្វ័យប្រវត្តិ បន្ទាប់ពីការធ្វើប្រតិបត្តិការបញ្ចប់វិក្កយបត្រ ដើម្បីបោះពុម្ពសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចេញពីប្រព័ន្ធ NRMIS។

-រជ្ជទេយ្យករចំណូល ឬ មន្ត្រីទទួលបន្ទុកប្រមូលចំណូល របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗត្រូវពិនិត្យសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួចបញ្ជូនមករតនាគាររាជធានី ខេត្ត ជាមុន តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម Telegram បន្ទាប់មកត្រូវបញ្ជូនដីកាសម្រេចសលាកបត្របង់ចំណូលថវិកាក្រុង ស្រុក ខណ្ឌប្រចាំខែ និងតារាងលម្អិតដីកាសម្រេចសលាកបត្របង់ចំណូលថវិកាប្រចាំខែ ដែលមានការចុះហត្ថលេខា (ច្បាប់ដើម) មករតនាគាររាជធានី ខេត្តតាមក្រោយ។

៤. ប្រាក់ចំណូលពីកម្រៃសេវាសាធារណៈដែលរជ្ជទេយ្យករចំណូល នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រមូលបាន ត្រូវបង់ទាំងអស់ទៅគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ បន្ទាប់ពីដកប្រាក់រង្វាន់រួច មុនចាប់ផ្តើមអនុវត្តប្រព័ន្ធ NRMIS។

៥. ការទូទាត់ប្រាក់រង្វាន់÷ ដើម្បីរៀបចំការទូទាត់ប្រាក់រង្វាន់ដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានដកកន្លងមក រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវប្រើប្រាស់ប្រព័ន្ធ NRMIS ដើម្បីកត់ត្រា ដោយត្រូវជ្រើសរើសយកសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបង្វែរចូលថវិការួចហើយ តាមរយៈសាច់ប្រាក់ដែលបានបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ។ បន្ទាប់មកត្រូវបោះពុម្ពលិខិតស្នើសុំផ្សេងៗ និងរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រេចសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបណ្ណបង់ប្រាក់, តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក និងផ្ញើមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីអនុវត្តនីតិវិធីបន្ត។ សម្រាប់ប្រតិបត្តិការចំណាយត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

៦. ប្រព័ន្ធ NRMIS នឹងត្រូវធ្វើសន្ទានកម្មជាមួយកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលរៀបចំដោយក្រសួងមហាផ្ទៃ ដើម្បីបង្កើតប្រតិបត្តិការក្នុងប្រព័ន្ធ NRMIS ដោយស្វ័យប្រវត្តិ។ ក្នុងករណីដែលប្រព័ន្ធ NRMIS ពុំទាន់អាចធ្វើសន្ទានកម្មជាមួយកម្មវិធីព័ត៌មានវិទ្យា

សម្រាប់គ្រប់គ្រងនិងផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌបាន រជ្ជទេយ្យករចំណូលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតប្រតិបត្តិការក្នុងប្រព័ន្ធ NRMIS ដោយផ្ទាល់ ឬ អាចធ្វើការបញ្ចូលប្រតិបត្តិការតាមរយៈទម្រង់ File Excel ដែលបានរៀបចំ និងផ្តល់ជូនដោយក្រុមការងារបច្ចេកទេសប្រព័ន្ធ NRMIS។

**៧.** រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀតទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូល និងធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីឱ្យប្រើប្រាស់វិក្កយបត្រដែលមានលេខកូដបង់ចំណូលជាកំហិត។

ទទួលបានសារាចរនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ២៤៣ ឧវនន.ករ.ប្រក

ថ្ងៃ ព្រហ. ១៣ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសេចក្ដីជូនដំណឹងលេខ១៤៦៤/២២ ក.អ.ក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ស្ដីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ស៊ីណូប្រោដ៍ អីកែរីល (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ីណូប្រោដ៍ អីកែរីល** (ខេមបូឌា) ឯ.ក **(SINOPROUD APPAREL (CAMBODIA) CO., LTD.)** តំណាងដោយលោក **FENG, SHUO** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ**EJ4372911** ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅផ្លូវលេខ១១៥ ភូមិព្រែករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំ ស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។
ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ីណូប្រាយ៍ អ៊ីភែរីល (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកណ្តាល
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល
-រដ្ឋបាលក្រុងតាខ្មៅ
-រដ្ឋបាលសង្កាត់កំពង់សំណាញ់
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសេចក្តីជូនដំណឹងលេខ១១៨៥/២២ ក.អ.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ជេ ថិច ហ្គាម៉ិន ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ជេ ថិច ហ្គាម៉ិន ឯ.ក **(J TEX GARMENT CO., LTD.)** តំណាងដោយលោក **JUNG HO YOUNG** សញ្ជាតិកូរ៉េ កាន់លិខិតឆ្លងដែនលេខ**M03844870** ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅអគារលេខ២ និងលេខ៤ ដីឡូត៍លេខ១ ផ្លូវជាតិលេខ៤ ភូមិវល្លិសរ ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំ ស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ ជេ ថិច ហ្គាម៉ិន ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
-រដ្ឋបាលស្រុកសំរោងទង
-រដ្ឋបាលឃុំវល្លិសរ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ...................

ថ្ងៃ........................ ខែ.............. ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..........ខែ.......... ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ១៦៧០/២២ ក.អ.ក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់ក្រុមហ៊ុន មេធូវី ប៊ែក & ខេស (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **មេធូវី ប៊ែក & ខេស (ខេមបូឌា) ឯ.ក (MATEWE BAG & CASE (CAMBODIA) CO., LTD.)** តំណាងដោយលោក **YANG, WENGUANG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EE3704293** ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ បង្កើតរោងចក្រ**ផលិតកាបូបគ្រប់ប្រភេទ** ដែលមានទីតាំងស្ថិតនៅ**ផ្លូវរទេះភ្លើង ដីឡូត៍លេខ៣១៤ ភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។**

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-កាបូប (ពីស្បែក) | ១៥១២ |
| ២-កាបូប (ពីប្លាស្ទិក) | ២២២០ |
| ៣-កាបូប (ពីកំណាត់) | ១៣៩២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **" រោងចក្រផលិតកាបូបគ្រប់ប្រភេទ មេដរី ប៊ែក & ខេស (ខេមបូឌា) ឯ.ក "**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

